ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តរតនគិរី** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម លី ធុជ | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស | ប្រធាន |
| ២. ឯកឧត្តម ហ៊ាន វណ្ណហាន | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. ឯកឧត្តម ណុះ ស្លេះ | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤. ឯកឧត្តម សូខន ឫទ្ធីគុណ | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ៥. ឯកឧត្តម ស ថាវី | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ឯកឧត្តម ពាស់ មូស្លីម | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៧. ឯកឧត្តម សង់ ស៊ីណារ៉ុង | អនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៨. ឯកឧត្តម ស៊ឹម សុខខេង | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. ឯកឧត្តម ម៉ី ហ៊ុល | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ១០. ឯកឧត្តម ប៉ែន វិបុល | អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ១១. ឯកឧត្តម ផាត បូណេ | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១២. ឯកឧត្តម ផាន់ ផល្លា | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. ឯកឧត្តម ហ៊ុន ប៊ុនថាន | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៤. ឯកឧត្តម ហ៊ឹម សុទិត្យា | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៥. ឯកឧត្តម សុះ ហ្វាស៊ី | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦. ឯកឧត្តម ហឿន សេងហាក់ | ទីប្រឹក្សា ក្រសួងព័ត៌មាន | សមាជិក |
| ១៧. ឯកឧត្តម សុខ សារ៉េត | ទីប្រឹក្សា ក្រសួងព័ត៌មាន | សមាជិក |
| ១៨. ឯកឧត្តម វ៉ាន់ សោភា | ទីប្រឹក្សា ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៩. ឯកឧត្តម អឿង សារិៈ | ទីប្រឹក្សា ក្រសួងព័ត៌មាន | សមាជិក |
| ២០. ឯកឧត្តម កុល ផាន់ណា | ទីប្រឹក្សា ក្រសួងព័ត៌មាន | សមាជិក |
| ២១. ឯកឧត្តម គាំ រីបូន | អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិអេស្កាប់ អាជ្ញាធរមីន | សមាជិក |
| ២២. ឯកឧត្តម ស៊ុយ ជីហ៊ាង | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ២៣. ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវត្ថ | អគ្គនាយក នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៤.ឯកឧត្តម គួច ចាន់នី | អគ្គនាយក នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៥. ឯកឧត្តម យ៉ា ប៊ុនណា | អគ្គនាយក នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២៦. ឯកឧត្តម មាស សុគន្ធ | អគ្គនាយករង នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២៧. ឯកឧត្តម ហ៊ាយ ភីរក្ស | អគ្គនាយករង នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៨. ឯកឧត្តម ហ៊ែល តូនី | អនុប្រធានអាជ្ញាធរទន្លេសាប នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២៩. ឯកឧត្តម ទុយ ស៊ីនណា | អគ្គនាយករង នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣០. ឯកឧត្តម ទេព កល្យាណ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ៣១. ឯកឧត្តម ចៅ ជីអាន | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ៣២. លោក មាស សុផល | អគ្គនាយកស្តីទី នៃក្រសួងបរិស្ថាន | សមាជិក |

| | | |
|---|---|---|
| ៣៣. **លោក ទូន សុផល** | អគ្គនាយករង នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣៤. **លោក តែ ប៊ុណ្ណារិទ្ធ** | អគ្គលេខាធិការរង នៃក្រសួងផែនការ | សមាជិក |
| ៣៥. **លោក ជាម ច័ន្ទកេណា** | អគ្គនាយករង នៃក្រសួងផែនការ | សមាជិក |
| ៣៦. **លោក ជីន សាំរិបុល** | អគ្គនាយករង នៃក្រសួងផែនការ | សមាជិក |
| ៣៧. **លោក ណៃ ចំណង់** | អគ្គនាយករង នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣៨. **លោក សួន វ៉ាន់ហុង** | អគ្គនាយករង នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៣៩. **លោកឧត្តមសេនីយ៍ទោ កែន តាវា** | មេបញ្ជាការរងកងទ័ពជើងគោក នៃក្រសួងការពារជាតិ | សមាជិក |
| ៤០. **លោក អ៊ិន សំបូរ** | អគ្គនាយករងវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៤១. **លោក អ៊ឹង វណ្ណា** | អគ្គនាយករង នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤២. **លោក ស៊ិន សារ៉ាឌី** | អគ្គនាយករង នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៤៣. តំណាងក្រសួងយុត្តិធម៌ | | សមាជិក |
| ៤៤. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ៤៥. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ៤៦. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីឲ្យចូលរួមក្នុងក្រុមការងារ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន រដ្ឋបាលខេត្តរតនគិរី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួលៈ*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*